| | | | |
|---|---|---|---|
| ២០- គណបក្សសាធារណរដ្ឋអភិវឌ្ឍន៍សេរី | | សរុបសម្លេងឆ្នោតបានការ | ១១.៧៤៤ |

**ប្រការ ២ :** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ហត្ថលេខា និង ត្រា

ព្រឹទ្ធាចារ្យ ឆេង ផុន

*****

រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៨

## សេចក្តីសំរេចលេខ ០៩.១៨២៨/៩៨ គ.ជ.ប

## ស្តីពី

## ការបែងចែកអាសនៈរដ្ឋសភា សំរាប់គណបក្សនយោបាយ ឈ្នះឆ្នោតក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ២ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨

*****

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីគណបក្សនយោបាយ
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០៤២ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ២
- យោងប្រកាសរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០៥/៨០៦/៩៨ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៨ ស្តីពីការប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនូវបទបញ្ជា និងនីតិវិធី សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ២
- បានឃើញ សេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៩.១៨២៧/៩៨ គ.ជ.ប ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៨ ស្តីអំពីលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ២

- មណ្ឌលខេត្តរតនគិរី ក្នុងចំនួនអាសនៈរួម១ ត្រូវបានទៅគណបក្សប្រជាជន ១កៅអី ។
- មណ្ឌលខេត្តសៀមរាប ក្នុងចំនួនអាសនៈរួម៦ ត្រូវបានទៅគណបក្ស សម រង្ស៊ី ១កៅអី គណបក្សហ្វ៊ុនស៊ិនប៉ិច ២កៅអី និងគណបក្សប្រជាជន ៣កៅអី ។
- មណ្ឌលក្រុងព្រះសីហនុ ក្នុងចំនួនអាសនៈរួម១ ត្រូវបានទៅគណបក្សប្រជាជន ១កៅអី ។
- មណ្ឌលខេត្តស្ទឹងត្រែង ក្នុងចំនួនអាសនៈរួម១ ត្រូវបានទៅគណបក្សប្រជាជន ១កៅអី ។
- មណ្ឌលខេត្តស្វាយរៀង ក្នុងចំនួនអាសនៈរួម៥ ត្រូវបានទៅគណបក្សហ្វ៊ុនស៊ិនប៉ិច ១ កៅអី និង គណបក្សប្រជាជន ៤កៅអី ។
- មណ្ឌលខេត្តតាកែវ ក្នុងចំនួនអាសនៈរួម ៨ ត្រូវបានទៅគណបក្ស សម រង្ស៊ី ១ កៅអី គណបក្សហ្វ៊ុនស៊ិនប៉ិច ៣កៅអី និងគណបក្សប្រជាជន ៤កៅអី ។
- មណ្ឌលក្រុងកែប ក្នុងចំនួនអាសនៈរួម១ ត្រូវបានទៅគណបក្សប្រជាជន ១កៅអី ។
- មណ្ឌលក្រុងប៉ៃលិន ក្នុងចំនួនអាសនៈរួម១ ត្រូវបានទៅគណបក្ស សម រង្ស៊ី ១កៅអី ។

សរុបក្នុងចំណោមអាសនៈទាំងអស់ ១២២ គណបក្ស សម រង្ស៊ី ទទួលបាន ១៥កៅអី គណបក្សហ្វ៊ុនស៊ិនប៉ិច ទទួលបាន ៤៣កៅអី និងគណបក្សប្រជាជនកម្ពុជា ទទួលបាន ៦៤កៅអី ។

ប្រការ ២ ៖ សេចក្តីសម្រេចនេះ មានអនុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ហត្ថលេខា និង ត្រា

ព្រឹទ្ធាចារ្យ **ឆេង ផុន**

*****

រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៨

## សេចក្តីសម្រេចលេខ ០៩.១៨៦២/៩៨ គ.ជ.ប

## ស្តីពី

## ការប្រកាសឈ្មោះបេក្ខជនតំណាងរាស្ត្រ ដែលត្រូវបានជាប់ឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ សម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨

*****

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ